**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ខេត្តកំពង់ធំ

**រដ្ឋបាលខេត្តកំពង់ធំ**
**គណៈកម្មការរៀបចំព្រឹត្តិការណ៍**
លេខ៖......០០១/១៩......ស.ជ.ណ

ថ្ងៃសុក្រ ៨កើត ខែភទ្របទ ឆ្នាំកុរ ឯកស័ក ព. ស.២៥៦៣
កំពង់ធំ ថ្ងៃទី ០៦ ខែកញ្ញា ឆ្នាំ២០១៩

# សេចក្តីជូនដំណឹង
## ស្តីពី
## ការបង្កើត "ក្លឹបបាល់ទាត់យុវជនខេត្តកំពង់ធំ" ដើម្បីចូលរួមក្នុង ពានរង្វាន់បាល់ទាត់ SOCCER LEAGUE លើកទី៥ ឆ្នាំ២០១៩

គណៈកម្មការរៀបចំព្រឹត្តិការណ៍បាល់ទាត់ ពានរង្វាន់យុវជនខេត្តកំពង់ធំ ឆ្នាំ២០១៩ មានកិត្តិយស សូមជម្រាបជូនដំណឹងដល់ បណ្តាក្លឹបបាល់ទាត់ទាំង២០ ដែលបានចូលរួមក្នុងព្រឹត្តិការណ៍បាល់ទាត់ ពានរង្វាន់យុវជនខេត្តកំពង់ធំ ឆ្នាំ២០១៩ ឲ្យបានជ្រាបថា ដើម្បីចូលរួមចំណែក លើកកម្ពស់វិស័យបាល់ទាត់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ពិសេសដើម្បីការផ្សារភ្ជាប់នូវ បទពិសោធន៍កីឡាបាល់ទាត់ខេត្តកំពង់ធំ ជាមួយនឹងថ្នាក់ជាតិ ក៏ដូចទូទាំងប្រទេស ឱ្យកាន់តែមានសកម្មភាពរស់រវើក និងរីកចម្រើនកាន់តែប្រសើរបន្ថែមទៀត សំដៅបណ្តុះស្មារតីស្រឡាញ់កីឡា សុខភាព ចៀសឆ្ងាយពីគ្រឿងញៀន ព្រមទាំងរឹតចំណងមិត្តភាព សាមគ្គីភាព និងបង្កើនភាពស្និតស្នាលរវាងយុវជន និងយុវជន គណៈកម្មការរៀបចំព្រឹត្តិការណ៍បាល់ទាត់ ពានរង្វាន់យុវជនខេត្តកំពង់ធំ ឆ្នាំ២០១៩ នឹងធ្វើការបង្កើត **ក្លឹបបាល់ទាត់យុវជនខេត្តកំពង់ធំ** ដើម្បីចូលរួមក្នុង **ពានរង្វាន់បាល់ទាត់** SOCCER LEAGUE **លើកទី៥ ឆ្នាំ២០១៩** ដែលរៀបចំឡើងដោយ **សហភាពសហព័ន្ធយុវជនកម្ពុជា** (**ស.ស.យ.ក**) នៅរាជធានីភ្នំពេញ នាពេលខាងមុខនេះ។

ក្នុងន័យនេះ គណៈកម្មការនឹងបើកឱកាសដល់ក្លឹបបាល់ទាត់ទាំងអស់ ក្នុងការចូលរួមតាមរយៈការបញ្ជូនកីឡាករឆ្នើម និងមានទេព្យកោសល្យ តំណាងឲ្យក្លឹបរបស់ខ្លួន ចូលរួមក្នុងការជ្រើសរើស សម្រិតសម្រាំងយកតែកីឡាករតែ២០នាក់ប៉ុណ្ណោះ ដើម្បីក្លាយជាកីឡាកររបស់ក្លឹបបាល់ទាត់យុវជនខេត្តកំពង់ធំ ដែលតំណាងឲ្យខេត្តកំពង់ធំទាំងមូល ដើម្បីចូលរួមក្នុង **ពានរង្វាន់បាល់ទាត់** SOCCER LEAGUE ដោយបន្ទុកចំណាយក្នុងការចូលរួមការប្រកួត ការហ្វឹកហាត់ និងសម្ភារៈ ផ្សេងៗទៀត ជាបន្ទុករបស់គណៈកម្មការ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **លោកប្រធានក្លឹប** ទាំងអស់ មេត្តាជ្រាបជាព័ត៌មាន និងស្នើផ្តល់នូវបញ្ជីឈ្មោះ កីឡាករឆ្នើម តំណាងក្លឹបរបស់ខ្លួន មកអនុគណៈកម្មការបច្ចេកទេស ឲ្យបានរួសរាន់ **ត្រឹមថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៩** ដើម្បីគណៈកម្មការមានលទ្ធភាពធ្វើការសម្រិតសម្រាំងជ្រើសរើសកីឡាករ សម្រាប់ត្រៀមចូលរួមប្រកួត ឲ្យបានទាន់ពេលវេលា។

សូម លោក **ប្រធានក្លឹបបាល់ទាត់** ទាំងអស់ ទទួលនូវការគោរពរាប់អានពីខ្ញុំ។

**ជ.គណៈកម្មការរៀបចំព្រឹត្តិការណ៍**
**ប្រធាន**

**យ៉ុង សេងគុណា**


__**លេខទូរសព្ទទំនាក់ទំនង៖**__

- លោក សួគ៌ ច័ន្ទតារា 077 713 171
- លោក ឃឹម សេង 011 904 511